ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

២១/៣

សាលាដំបូងខេត្តកណ្តាល

លេខៈ 1016

# ដីកាដំណោះស្រាយ

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូង ខេត្តកណ្តាល ។

-បានឃើញៈ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/ ០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

-បានឃើញៈ សំណុំរឿងព្រហ្មទណ្ឌលេខៈ ៦៨៨ អក ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកណ្តាល។

-បានឃើញៈ សំណុំរឿងស៊ើបសួរលេខៈ ១៥០ សស ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកណ្តាល ។

-បានឃើញៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ៦៥៤ ដកសស ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល។

-បានឃើញៈ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៩៧២ ដកសព ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

**ក្រោយពីបានស៊ើបសួរមូលចប់សព្វគ្រប់លើជនត្រូវចោទហើយ ឃើញថាៈ**

ឈ្មោះ [redacted] ពេជ្រតារា ភេទស្រី អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) នៅលីវ អានីតិជន ទោសពីមុនគ្មាន។(ក្រៅឃុំ)

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទៈ **អំពើលួច និងក្លែងបន្លំ** ប្រព្រឹត្តនៅភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៦, មាត្រា ៦២៦ និងមាត្រា ៦២៧ នៃ ក្រមព្រហ្មទណ្ឌ។

**អង្គហេតុមានដូចតទៅ**

កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ មានជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា បានចូលមកបម្រើការងារជាមន្ត្រីចុះកិច្ចសន្យានៅធនាគារស្ថាបនាសាខាស្រុកអង្គស្នួល ឃុំដំណាក់អំពិល ស្ថិតក្នុងភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានតួនាទីជាបេឡាធិការ(Teller) ។ ចាប់តាំងពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ ជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា បានលួចដកប្រាក់របស់អតិថិជន និងក្លែងបន្លំ ស្នាមមេដៃរបស់អតិថិជនជាបន្តបន្ទាប់ សរុបមានចំនួន ២៨ ប្រតិបត្តិការ សរុបជាប្រាក់មានចំនួន ៣០៧៨,២៥ (បីពាន់ចិតសិបប្រាំបីដុល្លារម្ភៃប្រាំសេន) ដុល្លារអាមេរិក។ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា បានដកប្រាក់ពីគណនីរបស់ឈ្មោះ [redacted] ផ្លើមវិសុទ្ធ ចំនួន ៩០០ (ប្រាំបួនរយ) ដុល្លារអាមេរិក ដោយប្រើវិធីក្លែងបន្លំស្នាមមេដៃរបស់អតិថិជនដដែល ក្រោយមកធនាគារចាប់បាន ទើបធ្វើកិច្ចសន្យាបញ្ឈប់ជននេះពីការងារ និងដាក់ពាក្យបណ្តឹងមកកាន់អយ្យការអមសាលាដំបូងខេត្តកណ្តាល តែម្តង។

# សំអាងហេតុ

១.តាមអង្គហេតុបានបង្ហាញថា ពិតជាកើតមាននូវ អំពើលួច និងក្លែងបន្លំ ប្រាកដមែន ដោយកាលពីថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០២២ ស្ថិតនៅភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល មានជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា បានធ្វើសកម្មភាពលួចដកប្រាក់របស់អតិថិជន និងក្លែងបន្លំស្នាមមេដៃរបស់អតិថិជន ជាបន្តបន្ទាប់ ។

២.តាមចម្លើយជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា បានឆ្លើយថា៖ ខ្លួនជាបុគ្គលិកនៅធនាគារស្ថាបនា សាខាស្រុកអង្គស្នួលឃុំដំណាក់អំពិល ស្ថិតនៅក្នុងភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល ដែលមានតួនាទីជាបេឡា ។ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ បុគ្គលិកគណនីទានឈ្មោះ [redacted] ឆ្លើមវិសុទ្ធ បានឱ្យខ្លួនដកប្រាក់ចំនួន ៥០ដុល្លារ ពីគណនីរបស់គាត់ ខ្លួនក៏បានដកប្រាក់ជូនឈ្មោះ [redacted]ម វិសុទ្ធ ចំនួន ៥០ ដុល្លារ រួចប្រគល់ឱ្យគាត់ភ្លាម ។ ក្រោយមកនៅថ្ងៃដដែល នៅពេលដែលប្រគល់ប្រាក់ចំនួន៥០ដុល្លារ ទៅឱ្យឈ្មោះ [redacted] ឆ្លើមវិសុទ្ធ ខ្លួនក៏ភាន់ច្រឡំដកប្រាក់ឱ្យបុគ្គលិកឈ្មោះ [redacted] ឆ្លើមវិសុទ្ធ ម្តងទៀតចំនួន៣៥០ដុល្លារ ។ បន្ទាប់មកភ្លាមៗនោះខ្លួនក៏ភាន់ច្រឡំម្តងទៀត ពីគណនីបុគ្គលិកឈ្មោះ [redacted]ឆ្លើម វិសុទ្ធ ចំនួន ៥០០ ដុល្លារ ។ ក្រោយមកខ្លួនក៏បានទាក់ទងតាមទូរស័ព្ទទៅឈ្មោះ [redacted]ឆ្លើម វិសុទ្ធ ដោយប្រាប់ថាខ្លួនភាន់ច្រឡំពីគណនីរបស់លោកគ្រូលើសហើយ បន្ទាប់មកឈ្មោះ [redacted]ឆ្លើម វិសុទ្ធ បានប្រាប់ខ្លួនថាមិនអីទេ ហើយបានប្រាប់ខ្លួនឲ្យដាក់ប្រាក់ដែលច្រឡំនោះចូលក្នុងគណនីវិញ រួចខ្លួនក៏បានដាក់ប្រាក់ចូលក្នុងគណនីរបស់ឈ្មោះ [redacted]ម វិសុទ្ធ វិញក្នុងថ្ងៃដដែល ។ ចំពោះការចោទប្រកាន់ខ្លួនថាបានដកប្រាក់សរុបចំនួន២៨ប្រតិបត្តិការ ដែលមានទឹកប្រាក់សរុប ៣០៧៨,២៥ ដុល្លារអាមេរិក ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។ ឃើញថា ចម្លើយនេះអាចឲ្យតុលាការជឿបាន ព្រោះថា ចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងភស្តុតាងនានាដែលជាឯក សារពាក់ព័ន្ធ ។

៣.តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខខា បានបញ្ជាក់ថា៖ កាលពីថ្ងៃកើតហេតុ បុគ្គលិកឈ្មោះ [redacted] ពេជ្រតារា បានចាប់ផ្ដើមធ្វើការលួចដកប្រាក់ពីគណនីរបស់អតិថិជនចំនួន ៣០០ ដុល្លារអាមេរិក តាមរយៈប័ណ្ណដកប្រាក់ដោយបានក្លែងបន្លំស្នាមមេដៃរបស់អតិថិជន ដើម្បីធ្វើការលួចដកប្រាក់ពីគណនីរបស់អតិថិជន ។ ក្រោយពីបានលួចដកប្រាក់ពីគណនីរបស់អតិថិជនបានសម្រេចហើយ បុគ្គលឈ្មោះ [redacted] ពេជ្រតារា គឺនៅតែបន្តប្រើប្រាស់វិធីនេះដដែល ដោយបានក្លែងបន្លំស្នាមមេដៃរបស់អតិថិជន ដើម្បីលួចដកប្រាក់របស់អតិថិជនជាបន្តបន្ទាប់ ។ ហេតុដល់ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ឈ្មោះ [redacted] ពេជ្រតារា បានធ្វើការលួចដកប្រាក់ពីគណនីរបស់អតិថិជនឈ្មោះ [redacted]ឆ្លើម វិសុទ្ធ ចំនួន ៩០០ ដុល្លារអាមេរិក ដោយប្រើវិធី ក្លែងបន្លំស្នាមមេដៃរបស់អតិថិជនតាមវិធីដដែល តែលើកនេះត្រូវបានខាងធនាគារ ស្ថាបនាសាខាស្រុកអង្គស្នួល ឃុំដំណាក់អំពិល ពិនិត្យឃើញថាឈ្មោះ [redacted] ពេជ្រតារា បានលួចដកប្រាក់របស់អតិថិជន និងក្លែងបន្លំស្នាមម្រាមដៃ និងពុំមានការអនុញ្ញាតពីអតិថិជនឡើយ ។ ឈ្មោះ [redacted] ពេជ្រតារា ក៏បានទទួលស្គាល់ថាខ្លួនពិតជាបានដកប្រាក់ចេញពីគណនីរបស់អតិថិជនឈ្មោះ [redacted]ឆ្លើម វិសុទ្ធ ដែលមានទឹកប្រាក់ចំនួន ៩០០ ដុល្លារអាមេរិក ពិតមែន តាមលិខិតទទួលស្គាល់ និងធានាអះអាង ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ហើយឈ្មោះ [redacted] ពេជ្រតារា បានដាក់ប្រាក់ទាំងនោះ ចូលទៅក្នុងគណនីរបស់អតិថិជនវិញផងដែរ ។ ចាប់តាំងពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ ហេតុមកដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ ឈ្មោះ [redacted] ពេជ្រតារា បានធ្វើការលួចដកប្រាក់របស់អតិថិជនចំនួន ២៨ ប្រតិបត្តិការ ដែលមាន ទឹកប្រាក់ស្មើនឹងចំនួន ៣.០៧៨,២៥ ដុល្លារអាមេរិក ហើយបុគ្គលឈ្មោះ [redacted] ពេជ្រតារា បានយកទៅប្រើប្រាស់ប្រយោជន៍ផ្ទាល់ខ្លួន ។ ឃើញថា ចម្លើយនេះគ្រាន់តែជាការអះអាងតែប៉ុណ្ណោះ ពុំមានភស្តុតាងជាឯកសារ ឬសាក្សីដាក់បន្ទុកគ្រប់គ្រាន់ឡើយ ។

៤.ទាំងចម្លើយជនត្រូវចោទ និងចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងនានាដែលជាឯកសារពាក់ព័ន្ធ អាចកំណត់បានថាជនត្រូវចោទគឺមិនមានពាក់ព័ន្ធនឹងការចោទប្រកាន់ ពីបទ អំពើលួច និងក្លែងបន្លំ ទេ ព្រោះថា ជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា បានភាន់ច្រឡំដកប្រាក់ចេញពីគណនីរបស់ឈ្មោះ [redacted] ឆ្លើមវិសុទ្ធ

សរុបចំនួន ៩០០ដុល្លារ ។ ប៉ុន្តែនៅថ្ងៃដដែល ពេលដែលឈ្មោះ [redacted] ពេជ្រតារា ដឹងថា ខ្លួនបានដកប្រាក់ពីគណនីឈ្មោះ [redacted] ផ្ទើម វិសុទ្ធ លើស ក៏បានទាក់ទងតាមទូរស័ព្ទទៅឈ្មោះ [redacted] ផ្ទើម វិសុទ្ធ ដោយប្រាប់ថា ខ្លួនភាន់ច្រឡំពីគណនីរបស់លោកលើសហើយ បន្ទាប់មកឈ្មោះ [redacted] ផ្ទើម វិសុទ្ធ បានប្រាប់អោយឈ្មោះ [redacted] ពេជ្រតារា ដាក់ប្រាក់ដែលច្រឡំនោះចូលក្នុងគណនីនិងបានបញ្ចប់រឿង ។

៥.អំពើរបស់ជនត្រូវចោទ គឺបានភាន់ច្រឡំដកប្រាក់ចេញពីគណនីឈ្មោះ [redacted] ផ្ទើមវិសុទ្ធ សរុបចំនួន ៩០០ដុល្លារ ប៉ុន្តែជនត្រូវចោទបានជូនដំណឹងតាមទូរស័ព្ទទៅឈ្មោះ [redacted] វិសុទ្ធ អំពីការខ្លួនភាន់ច្រឡំនោះ ហើយឈ្មោះ [redacted] វិសុទ្ធ បានប្រាប់អោយជនត្រូវចោទដាក់ប្រាក់ដែលច្រឡំនោះចូលក្នុងគណនីវិញ ។ ឃើញថា អំពើរបស់ជនត្រូវចោទពុំមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសព្រហ្មទណ្ឌឡើយ គប្បីតុលាការសម្រេចលើកលែងចោទប្រកាន់លើជនត្រូវចោទពីបទ៖ អំពើលួច និងក្លែងបន្លំ ប្រព្រឹត្តនៅភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៦, មាត្រា ៦២៦ និងមាត្រា ៦២៧ នៃ ក្រមព្រហ្មទណ្ឌ ។

៦.ពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ [redacted] **ពេជ្រតារា** ដែលមានសាវតាជាតិដូចខាងលើ ពីបទ៖ **អំពើលួច** និងក្លែងបន្លំ ប្រព្រឹត្តនៅភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៦, មាត្រា ៦២៦ និងមាត្រា ៦២៧ នៃ ក្រមព្រហ្មទណ្ឌ។

៧.តាមដីការសន្និដ្ឋានស្ថាពរលេខ: ៩៧២ ដកសព ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២២ បានសម្រេចលើកលែងចោទប្រកាន់លើជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា ពីបទ **អំពើលួច និងក្លែងបន្លំ** ប្រព្រឹត្តនៅភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៦, មាត្រា ៦២៦ និងមាត្រា ៦២៧ នៃ ក្រមព្រហ្មទណ្ឌ។ ឃើញថា មានសំអាងហេតុសមស្រប គប្បីតុលាការលើកយកមកពិចារណា ។

**<u>ហេតុដូច្នេះសម្រេច</u>**

លើកលែងចោទប្រកាន់លើជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា ភេទស្រី អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើតភូមិបាត់ដឹង ឃុំត្រែងត្រយឹង? ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) នៅលីវ អានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

<u>ពីបទ៖</u> **អំពើលួច និងក្លែងបន្លំ** ប្រព្រឹត្តនៅភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៦, មាត្រា ៦២៦ និងមាត្រា ៦២៧ នៃ ក្រមព្រហ្មទណ្ឌ ។

ថ្ងៃ [illegible] ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ធ្វើនៅខេត្តកណ្តាល ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០២២
**ចៅក្រមស៊ើបសួរ**

[redacted]

បានទទួលដំណឹងរួចហើយ
ថ្ងៃទី ០៩ ខែ [illegible] ឆ្នាំ២០២១
តំណាងអយ្យការ

[redacted]